# បង្កើនគុណភាព! IMPACT 2020

**First 5 San Joaquin**

ព្រឹត្តប័ត្រព័ត៌មានសង្ខេបនៃការវាយតម្លៃ | ខែសីហា ឆ្នាំ 2021

អ្នកផ្តល់សេវាថែទាំកុមារនៃកម្មវិធី គ្រួសារ មិត្តភក្តិ និងអ្នកជិតខាង (FFN) ដើរតួនាទីយ៉ាងសំខាន់ក្នុងការបំពេញតម្រូវការថែទាំកុមាររបស់គ្រួសារ។ *ការបង្កើនគុណភាព!* របស់ First 5 San Joaquin's (F5SJ) *Raising Quality!* IMPACT 2020 FFN Initiative (*Raising Quality!* IMPACT 2020) មានគោលបំណងលើកកម្ពស់គុណភាពនៃការថែទាំដែលផ្តល់ដោយលោកយាយលោកតានៅក្នុងសហគមន៍ជនជាតិអាមេរិកអាហ្វ្រិក អាមេរិកឡាទីន និងអាមេរិកអាស៊ីអាគ្នេយ៍។ F5SJ បានផ្តល់មូលនិធិដល់អង្គការចំនួនបី (APSARA, El Concilio, និង Mary Magdalene Community Services) ដើម្បីផ្តល់នូវការពង្រឹងគុណភាព ការគាំទ្រ សម្ភារៈ និងការបណ្តុះបណ្តាលដល់លោកយាយលោកតានៅក្នុងសហគមន៍ទាំងនេះ។ ព្រឹត្តប័ត្រព័ត៌មានសង្ខេបនេះបង្ហាញពីការរៀនសូត្រពីការអនុវត្ត និងអនុសាសន៍ផ្សេងៗសម្រាប់ឆ្នាំក្រោយនៃគំនិតផ្តួចផ្តើម។

**ការចុះឈ្មោះ IMPACT** IMPACT បានគាំទ្រលោកយាយលោកតាដែលមានសវតាពូជសាសន៍និងជាតិពិន្ទុផ្សេងៗគ្នា។ ក្នុងចំណោមលោកយាយលោកតាចំនួន 57 នាក់ដែលបានចុះឈ្មោះនៅ IMPACT , 27 នាក់ជាជនជាតិខ្មែរ 17 នាក់ជាជនជាតិស្បែកខ្មៅឬអាមេរិកអាហ្វ្រិក ហើយ 13 នាក់ទៀតជាជនជាតិអាមេរិកឡាទីន។ សរុបមក លោកយាយលោកតាទាំងនេះបានមើលថែក្មេងៗចំនួន 87 នាក់ ក្នុងនោះមានទារក 20 នាក់ កូនក្មេងតូចចំនួន 28 នាក់ និងកុមារអាយុថ្នាក់មត្តេយ្យចំនួន 39 នាក់។




> *"ការលើកទឹកចិត្តអ្នកណាម្នាក់ឱ្យអានឱ្យចៅៗរបស់ពួកគេ ឬក៏អាចចំណាយពេលល្អជាមួយលោកតារបស់ពួកគេ ដែលបង្កើតផលប៉ះពាល់ពេញមួយជីវិតលើគ្រួសារ... វាមិនត្រឹមតែផ្លាស់ប្តូររបៀបដែលលោកយាយលោកតាទាក់ទងជាមួយកុមារប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្លាស់ប្តូរពីរបៀបដែលមាតាបិតាពិតប្រាកដមានទំនាក់ទំនងជាមួយកុមារផងដែរ។*
> *- អ្នកម៉ៅការ*

**លោកយាយលោកតាដែលចូលរួមក្នុង IMPACTបានបង្ហាញចំណាប់អារម្មណ៍ថាពួកគាត់៖**

- យល់ពីគោលដៅកម្មវិធី និងបង្កើតទំនាក់ទំនងប្រកបដោយទំនុកចិត្តជាមួយបុគ្គលិក។
- ទទួលបានអត្ថប្រយោជន៍ពីសេវាកម្មផ្ទាល់ដែលមានគម្លាតសង្គម និងតាមប្រព័ន្ធអនឡាញ ដូចជាការដឹកជូននូវសម្ភារៈ និងការចូលរួមក្នុងសិក្ខាសាលាផ្តល់ព័ត៌មានដែលធ្វើឡើងតាមរយៈការប្រជុំជាក្រុម។
- បានរៀនពីយុទ្ធសាស្ត្រថ្មីៗដើម្បីចូលរួមជាមួយចៅៗរបស់ពួកគេតាមរយៈកម្មវិធីចែករំលែកសៀវភៅបង្កើនអ្នកអាន។

> *តើអ្នកមានកូនដែរឬទេ? តើនរណាមើលថែពួកគេ? តើលោកតាមានមើលថែពួកគេដែរឬទេ? ព្រោះយើងមានកម្មវិធីដែលអាចជួយបាន!*
> *–អ្នកម៉ៅការ*

**យុទ្ធសាស្ត្រផ្សព្វផ្សាយជោគជ័យ។** អ្នកម៉ៅការបានចែករំលែកយុទ្ធសាស្ត្រដែលមានប្រយោជន៍បំផុតក្នុងការជ្រើសរើសលោកយាយលោកតា៖

- ស្វែងរកលោកយាយលោកតាដែលធ្លាប់ស្គាល់ជាមួយទីភ្នាក់ងារនេះ។
- ការទាក់ទងសហគមន៍ផ្តោតលើជំនឿ
- ការលើកទឹកចិត្ត "ការនិយាយប្រាប់តគ្នា" និង
- ការផ្សព្វផ្សាយការគាំទ្រកម្មវិធី។

**អ្នកម៉ៅការបានណែនាំលោកយាយលោកតាអំពីសេវាកម្មបន្ថែម។**

- កង្វល់អំពីការអភិវឌ្ឍន៍
- ការចាក់វ៉ាក់សាំងកូវីដ-19
- ការទទួលបានអាហារដែលមានតម្លៃទាប
- សេវាកម្មអន្តោប្រវេសន៍

## អនុសាសន៍សម្រាប់ពេលអនាគតនៃ *ការបង្កើនគុណភាព!* គំនិតផ្តួចផ្តើម FFN ៖

- ពង្រីក *ការបង្កើនគុណភាព!* ដើម្បីស្វែងរកលោកយាយលោកតាបន្ថែមទៀត
- បន្តបង្កើនលទ្ធភាពទទួលបានសម្ភារៈ និងធនធាននានាសមស្របតាមអាយុសម្រាប់ការលេងរបស់លោកយាយលោកតា
- លើកទឹកចិត្តឱ្យមានការចូលរួមកាន់តែច្រើនពីមាតាបិតា ក៏ដូចជាលោកយាយលោកតាផងដែរ
- ផ្តល់អាទិភាពដល់ឱកាសផ្ទាល់ខ្លួនសម្រាប់លោកយាយលោកតាជួបជុំគ្នា ធ្វើទំនាក់ទំនងសង្គម និងចែករំលែកការរៀនសូត្រនៅពេលដែលជំងឺរាតត្បាតបានធូរស្រាល
- ធ្វើការធានាថា *ការបង្កើនគុណភាព!* ធាតុកម្មវិធី និងកាលវិភាគនៃការអនុវត្តត្រូវនឹងតម្រូវការរបស់អ្នកម៉ៅការ